## សំរេច

១-បដិសេធពាក្យបណ្តឹងជំទាស់ លេខ ១៦២/៩៨ នគក ចុះថ្ងៃទី១១ ខែ សីហា ឆ្នាំ ១៩៩៨ របស់គណបក្សហ៊្វុនស៊ិនប៉ិច ដែលទាក់ទងនឹងសេចក្តីសំរេច របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លេខ០៨-១៧១០/៩៨ គជប ចុះថ្ងៃទី១១ ខែ សីហា ឆ្នាំ ១៩៩៨ ក្នុងការបដិសេធពាក្យបណ្តឹង លេខ ០៣៥-៩៨ នគក ចុះថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ១៩៩៨ ដែលប្តឹងពីរឿង: ឆា ប្រធានអណ្តូងភូមិត្រពាំងឈើ ឃុំតាបកាំង ស្រុកភ្នំស្រួច ពីរបៀបបញ្ចុះបញ្ចូលប្រជាពលរដ្ឋអោយបោះឆ្នោតអោយគណបក្សប្រជាជន ដោយជាអាសការ ។

២-តម្កល់សេចក្តីសំរេច របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លេខ ០៨-១៧១០/៩៨ គជប ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ១៩៩៨ ទុកជាបានការពេញទាំងមូល ។

៣-សេចក្តីសំរេចនេះធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ១៩៩៨ ពេលអង្គប្រជុំពេញអង្គ នៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសំរេចស្ថាពរមិនអាចប្តឹងតវ៉ា ។

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ — ចម្លងត្រឹមត្រូវតាមច្បាប់ដើម

ហត្ថលេខា និងត្រា — លេខាធិការ

**ចាន់ សុខ** — **ម៉េង គឹមលី**

★★★

ភ្នំពេញ,ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ១៩៩៨

## សេចក្តីសំរេច លេខ ១៤ កបធ/សសរ

## ក្រុមប្រឹក្សាធម្មនុញ្ញ

****

-បានឃើញថា : ការចូលរួមទៅបោះឆ្នោតរបស់ប្រជាជនយ៉ាងច្រើនកុះករមិនអាចបង្ហាញសញ្ញាថា មានប្រធានភូមិ ឃុំ ស្រុកដឹកនាំប្រជាជនជាក្រុមៗទៅបោះឆ្នោតបានទេ ។

-បានឃើញថា :កំណត់ហេតុនៃការបោះឆ្នោត គជប ១១០១ គកប របស់គណៈកម្មការការិយាល័យបោះឆ្នោត និងកំណត់ហេតុនៃការប្រកាសលទ្ធផលការរាប់សន្លឹកឆ្នោត របស់គណៈកម្មការ ឃុំ-សង្កាត់រៀបចំការបោះឆ្នោត ភាគច្រើនសុទ្ធតែមានការចុះហត្ថលេខាពីភ្នាក់ងារគណបក្សនានា ហើយក្នុងនោះក៏មានភ្នាក់ងារ គណបក្សហ៊្វុនស៊ិនប៉ិច ផងដែរ នេះសបញ្ជាក់ថា ភ្នាក់ងារគណបក្សនានាបានទទួលស្គាល់ការបោះឆ្នោត និងការប្រកាសលទ្ធផលសន្លឹកឆ្នោតនៅគណៈកម្មការឃុំ-សង្កាត់រៀបចំការបោះឆ្នោតទុកជាត្រឹមត្រូវហើយ ។

-បានឃើញថា : ក្នុងចំណោមការទាំងពីរនេះគ្មានបណ្តឹងណាមួយពីភ្នាក់ងារគណបក្សណាមួយក្នុងពេលនោះ នេះកាន់តែបញ្ជាក់ច្បាស់ថែមទៀតថា ដំណើរការបោះឆ្នោតនៅការិយាល័យបោះឆ្នោត និងក្នុងការរាប់សន្លឹកឆ្នោត នៅគណៈកម្មការឃុំ-សង្កាត់រៀបចំការបោះឆ្នោតបានប្រព្រឹត្តទៅដោយគ្មានភាពមិនប្រក្រតីណាមួយធ្ងន់ធ្ងរអាចប៉ះពាល់ដល់លទ្ធផលឡើយ ។

-យល់ឃើញថា : ពាក្យបណ្តឹងនេះគ្មានវត្ថុការណ៍គ្រប់គ្រាន់ ដើម្បីបើកសវនាការតាមមាត្រា១១៧ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ គប្បីក្រុមប្រឹក្សាធម្មនុញ្ញសំរេចបដិសេធពុំទទួលពាក្យបណ្តឹងតវ៉ានេះ ។

-យល់ឃើញថា : សេចក្តីសំរេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លេខ ០៨-១៧១១/៩៨ គជប ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ ១៩៩៨ មានលក្ខណៈត្រឹមត្រូវហើយ ។

**សំរេច**

១-បដិសេធពាក្យបណ្តឹងជំទាស់ លេខ ១៦២/៩៨ នគក ចុះថ្ងៃទី១១ ខែ សីហា ឆ្នាំ ១៩៩៨ របស់គណបក្សហ្វ៊ុនស៊ិនប៉ិច ដែលទាក់ទងនឹងសេចក្តីសំរេច របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លេខ០៨-១៧១១/៩៨ គជប ចុះថ្ងៃទី១១ ខែ សីហា ឆ្នាំ ១៩៩៨ ក្នុងការបដិសេធពាក្យបណ្តឹង លេខ ០៥៦-៩៨ នគក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៨ ស្តីពីភាពមិនប្រក្រតីរបស់ស្រុកឧត្តុង្គ និងប្រធានភូមិ-ឃុំ ពីបទទិញសន្លឹកឆ្នោត ខេត្តកំពង់ស្ពឺ ។

២-តម្កល់សេចក្តីសំរេច របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លេខ ០៨-១៧១១/៩៨ គជប ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ១៩៩៨ ឱ្យជាបានការពេញទាំងមូល ។

៣-សេចក្តីសំរេចនេះធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ១៩៩៨ នាសម័យប្រជុំពេញអង្គ នៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសំរេចស្ថាពរបិទផ្លូវតវ៉ា ។

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ — ដកស្រង់ត្រឹមត្រូវតាមច្បាប់ដើម

ហត្ថលេខា និងត្រា — លេខាធិការ

**ចាន់ សុខ** — **ម៉េង គីមលី**

★★★

ភ្នំពេញ,ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ១៩៩៨

## សេចក្តីសំរេច លេខ ១៥ កបធ/សសរ

## ក្រុមប្រឹក្សាធម្មនុញ្ញ

****

-យល់ឃើញថា : ពាក្យបណ្តឹងជំទាស់លេខ ១៦២-៩៨ នគក ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ១៩៩៨ របស់គណបក្សហ្វ៊ុនស៊ិនប៉ិច ដែលទាក់ទងនឹងសេចក្តីសំរេច របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតលេខ ០៨-១៦០៩/៩៨ គជប ចុះថ្ងៃទី១១ ខែ សីហា ឆ្នាំ ១៩៩៨ ដែលបដិសេធពាក្យបណ្តឹងលេខ ០៥៧/៩៨ នគក ចុះថ្ងៃទី០៥ ខែ សីហា ឆ្នាំ១៩៩៨ ដោយចោទពីភាពមិនប្រក្រតីរបស់ស្រុកឧត្តុង្គ និងបំពានសិទ្ធភ្នាក់ងារសង្កេតការណ៍ ដោយមូលហេតុក្នុងពេលរាប់សន្លឹកឆ្នោត អ្នកសង្កេតការណ៍របស់គណបក្សប្រឆាំង ត្រូវបានគណៈកម្មការមិនអោយមើលតារាងគូស និង ឯកភាពផងទេ មិនត្រឹមត្រូវទេ ។